ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៨៣៨ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.០៦...ខែ.កុម្ភៈ.ឆ្នាំ ២០១៥

សូមគោរពជូន

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃព្រឹទ្ធសភា

-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃរដ្ឋសភា

-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

-ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅរមក្រសួងព្រះបរមរាជវាំង

-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា

-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា

-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ឯកឧត្តមនាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់

**កម្មវត្ថុ** ÷ របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែមករា ឆ្នាំ២០១៥** និងទិសដៅអនុវត្តបន្ត ។

ន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមផ្ញើជូនឯកឧត្តម នូវរបាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែមករា ឆ្នាំ២០១៥** ចំនួន០១ច្បាប់ ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**ចម្លងជូន**

-គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង

-ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍

# ស្តីពី

# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែមករា ឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

ក្នុងខែមករា ឆ្នាំ២០១៥នេះ ស្ថានភាពការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៤ ត្រូវបានបញ្ចប់ជាស្ថាពរហើយ។ រីឯល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន១១១,៥៨ភាគរយនៃផែនការ និងកំពុងដំណើរការប្រមូលផលជាបណ្តើរៗនៅតាមខេត្តមួយចំនួន(ក្រចេះ ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង តាកែវ និងត្បូងឃ្មុំ)។ នៅពាក់កណ្តាលខែមករា ឆ្នាំ២០១៥កន្លងមកនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលបឋមការងារបង្កបង្កើនផលឆ្នាំ២០១៤-២០១៥ ដើម្បីវាយតម្លៃតុល្យភាពស្បៀងជំហានដំបូងសម្រាប់ឆ្នាំ២០១៥ និងលើកទិសដៅអនុវត្តបន្តចំពោះមុខ ដើម្បីបង្កើនផលិតភាពកសិកម្មនៅលើតំបន់ដែលមានសក្តានុពលដាំដុះបន្ទាប់ពីការប្រមូលផលស្រូវរដូវវស្សា និងរដូវប្រាំង តាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របដើម្បីបង្កើនសេដ្ឋកិច្ចគ្រួសារ។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងខែមករា ឆ្នាំ២០១៥នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលបញ្ចប់ការប្រមូលផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៤

ជារួមផ្ទៃដីអនុវត្តសរុបចំនួន២.៥៦៤.៥៧២ហិកតា ស្មើនឹង១០៦,៣៦ភាគរយ នៃផែនការ២.៤១១.២០៧ហិកតា តិចជាងឆ្នាំមុនចំនួន៣.១៥១ហិកតា ក្នុងនោះ ការងារប្រមូលផលស្រូវសម្រេចបានលើផ្ទៃដីសរុបចំនួន២.៥៣៧.៩៧៦ហិកតា លើសឆ្នាំមុន៥២.៤៥៥ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៧.០៨៩.២៤៨តោន តិចជាងឆ្នាំមុន១៨២.០០៣តោន និងទិន្នផលជាមធ្យមចំនួន២,៧៩៣តោនក្នុងមួយហិកតា(ឆ្នាំមុនទិន្នផលមធ្យម២,៩២៥តោនក្នុងមួយហិកតា)។

#### ១.២ ដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៤-២០១៥

គិតមកទល់ពេលនេះ ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានលើផ្ទៃដីសរុបចំនួន៥៨.២៧១ហិកតា ស្មើនឹង១២,៥៣ភាគរយ នៃផ្ទៃដីអនុវត្តបានចំនួន៤៦៥.២៣០ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន២៦៩.៣៣៥តោន និងទិន្នផលជាមធ្យមចំនួន៤,៦២២តោនក្នុងមួយហិកតា ក្នុងនោះ៖

- ផ្ទៃដីភ្ជួររាស់សរុបចំនួន៥៤២.៦៧៣ហិកតា លើសឆ្នាំមុនចំនួន៥៦.៩៨៣ហិកតា
- ផ្ទៃដីសាបសរុបចំនួន៤.០១២ហិកតា តិចជាងឆ្នាំមុនចំនួន៧៥៤ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៤៦៥.២៣០ហិកតា ស្មើនឹង១១១,៥៨ភាគរយនៃផែនការ៤១៦.៩៦៥ហិកតា លើសឆ្នាំមុនចំនួន៤០.២២៣ហិកតា។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
No. 200 Preah Norodom Blvd. Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

### ១.៣ លទ្ធផលប៉ាន់ស្មានតុល្យភាពស្បៀងសម្រាប់ឆ្នាំ២០១៥

តាមរយៈលទ្ធផលបូកសរុបបឋមការងារបង្កបង្កើនផលបានបង្ហាញថា ស្ថានភាពប្រែប្រួលមិនអំណោយផលនៃអាកាសធាតុក្នុងឆ្នាំកន្លងមកនេះបានបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ការងារបង្កបង្កើនផល ធ្វើឲ្យផ្ទៃដីដាំដុះបានធ្លាក់ចុះបន្តិចក៏ដូចជាការលូតលាស់របស់ដំណាំផងដែរ ជាពិសេសការធ្លាក់ចុះដំណាំស្រូវរដូវវស្សា។ បរិមាណផលស្រូវអាចទទួលបានពីការងារបង្កបង្កើនផលពីឆ្នាំ២០១៤-២០១៥មានដូចខាងក្រោមៈ

| កម្រិតកំណត់ | ឯកតា | រដូវវស្សា | រដូវប្រាំង | សរុប |
|---|---|---|---|---|
| - ផែនការដាំដុះ | ហត | ២.៤១១.២០៧ | ៤១៥.៩៣០ | ២.៨២៧.១៣៧ |
| - ផ្ទៃដីអនុវត្ត | ហត | ២.៥៦៤.៥៧២ | ៤៨៧.៥១១ | ៣.០៥២.០៨៣ |
| - ផ្ទៃដីខូចខាត | ហត | ៤៥.៩៤០ | ១៧០ | ៤៦.១១០ |
| - ផ្ទៃដីស្តារបាន | ហត | ១៩.៣៤៤ | ០ | ១៩.៣៤៤ |
| - ផ្ទៃដីប្រមូលផល | ហត | ២.៥៣៧.៩៧៦ | ៤៨៧.៣៤១ | ៣.០២៥.៣១៧ |
| - ទិន្នផលមធ្យម | ត/ហត | ២,៧៩៣ | ៤,៤០១ | ៣,០៥២ |
| - បរិមាណផលសរុប | តោន | ៧.០៨៩.២៤៨ | ២.១៤៤.៧២៨ | ៩.២៣៣.៩៧៦ |

### ១.៤ តុល្យស្បៀងសម្រាប់ឆ្នាំ២០១៥

- កាត់ចេញ១៣%សម្រាប់ទុកពូជ ចំណីសត្វ និងបាត់បង់ដោយការប្រមូលផល ១.២០០.៤១៧តោន
- ស្រូវនៅសល់ជាស្បៀង ៨.០៣៣.៥៥៩តោន
- សរុបបរិមាណស្បៀងជាអង្ករ (អត្រាកិនជាអង្ករ៦៤%) ៥.១៤១.៤៧៨តោន
- តម្រូវការស្បៀងជាអង្ករ (ប្រជាជនចំនួន១៥.២៣១.១២៦ នាក់ x១៤៣គ.ក្រ/១នាក់/ឆ្នាំ) ២.១៧៨.០៥១តោន
- *អតិរេកអង្ករ* *២.៩៦៣.៤២៧តោន*
- *អតិរេកស្រូវ* *៤.៦៣០.៣៥៤តោន*

### ១.៥ ដំណាំរួមផ្សំរដូវប្រាំង :

- ផ្ទៃដីសម្រេចបានចំនួន៥១.៧៩៦ហិកតា ស្មើនឹង១១៩,៩៨% នៃផែនការចំនួន៤៣.១៦៩ហិកតា តិចជាងឆ្នាំមុនចំនួន២.៧៦៩ហិកតា។

- ដំណាំឧស្សាហកម្ម : ផ្ទៃដីសម្រេចបាន១២.៤១៧ហិកតា ស្មើនឹង៦១,៣២% នៃផែនការ២០.២៥១ហិកតា លើសឆ្នាំមុនចំនួន១.៥៨០ហិកតា។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិ-ឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ៥៧,២៩ | ៥៦,២០ |
| សរុប I | | ៤០៦,៦០ | ៣៤៤,៣១ | ៥៧,២៩ | ៥៦,២០ |
| II-ចម្ការកៅស៊ូកសិ-ឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុកគ្គិនីកា អ៊ិនវេសមេន គ្រុប | ១០.៧១៩,២៧ | ៥.៣២៧,០៥ | ៤.១០៧,៨៦ | ១.០៩២,៤០ |
| ២ | ក្រុមហ៊ុន ស៊ីហ្សាប់បេីលីមីធីត (រតនគីរី) | ៧៨,៥៣ | ២.០៦៤,៣០ | ២១៤,៣២ | - |

| | | | | | |
|---|---|---|---|---|---|
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ១.០៨២,១២ | ១៣០,៥៤ | ១០៣,១០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.៥៧១,៥២ | ៣.១៣៩,៨៣ | ៩១១,៩៧ | ៤៦១,៦០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.៣៤៦,៦៩ | ១.០១៥,៧៧ | ២៥៦,៩០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វរីសស៍ (ស្នួល) | ១.៧៤៤,៧៨ | ២.៦៤១,៤៣ | ៤៨៦,៧១ | ១៨២,៤០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០២៩,៧០ | ១.២៣៧,៥៩ | ៦១៨,៥០ | ១០៩,០០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្ដូង) | ៣.១១១,៦៥ | ១.២១៥,៥៥ | ៥៩៣,១៥ | ១៣៩,៣០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ១.២៧២,៦០ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.៣៤៧,៩២ | ១.៣២៧,៦៥ | ៣៥២,២០ |
| សរុប II | | ២៨.១៥៩,៥៤ | ២៥.៦៧៥,០៨ | ៩.៤០៦,៤៧ | ២.៦៩៦,៩០ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៧០៨,០០ | ១៤១.២០៤,០០ | ១៣,២៩ | ១៣,២០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៦១.២៧១,០០ | ៧៦.១៤៧,០០ | ៦.១៧០,០០ | ៥.៦២៥,០០ |
| សរុប III | | ៦១.៩៧៩,០០ | ២១៧.៣៥១,០០ | ៦.១៨៣,២៩ | ៥.៦៣៨,២០ |
| សរុប I+II+III | | ៩០.៥៤៥,១៤ | ២៤៣.៣៧០,៣៩ | ១៥.៦៤៧,០៥ | ៨.៣៩១,៣០ |

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ធ្វើតេស្តសំណាកយថាប្រភេទចំនួន២៤សំណាក ដើម្បីបញ្ជាក់គុណភាពកៃច្នៃរបស់រោងចក្រក្រុមហ៊ុន ឡុង ស្រេង
- រៀបចំពិធីសារពិសោធន៍ស្ដីពីការប្រើប្រាស់ជីលើកៅស៊ូក្លូន GT1 និង RRIM712 និងវាស់ទំហំដើមលើចម្ការពិសោធន៍ IRAE9, IRAE17, IRAE18
- វិភាគសរីរៈទឹកជ័រតាមចម្ការពិសោធន៍នីមួយៗ និងស្រង់ទិន្នន័យទិន្នផលជ័រគ្រប់ចម្ការពិសោធន៍
- ត្រួតពិនិត្យឡូត៍ពិសោធន៍ក្លូន និងដាំពង្រីកច្បារពូជកៅស៊ូ និងថែទាំសមុហកម្មពូជដំណាំគម្របដី
- ធ្វើជំរឿនកូនកៅស៊ូក្នុងឡូត៍ PV.AA.11 នៅក្រុមហ៊ុនចម្ការកៅស៊ូទ្រីភាពបឹងទន្លេម្រេច ស្រុករៀង ខេត្តព្រះវិហារ
- កាប់ព្រៃតាមចន្លោះរងក្នុងឡូត៍នីមួយៗ លាបថ្នាំរំញោចនិងលាបខ្លាញ់គោ
- ដឹកនាំនិស្សិតសរសេរសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង និងសាលាជាតិកសិកម្មកំពង់ចាម។

## ៣ ផ្នែកផលិតកម្មនិងបសុពេទ្យាបាល

### ៣.១ ការងារវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ

- ជ្រូកសរុបចំនួន២៣៩ក្បាល នៅក្នុងស្ថានីយពិសោធន៍ពូជជ្រូក ក្នុងនោះជ្រូកបាចំនួន១០ក្បាល ជ្រូកមេចំនួន៩២ក្បាល និងកូនជ្រូកចំនួន១២៧ក្បាល
- គោសរុបចំនួន១៥៧ក្បាល នៅក្នុងស្ថានីយចិញ្ចឹមគោ ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៣៥ក្បាល គោជំទង់ចំនួន៣៨ក្បាល គោបៅដោះចំនួន៣៩ក្បាល និងគោកំផែងសែនចំនួន៤១ក្បាល
- វិទ្យាស្ថានបានខិតខំពង្រឹងសកម្មភាពពិសោធន៍ស្រាវជ្រាវដូចខាងក្រោម៖
  + កែច្នៃទឹកមេជីវិតនៅវិទ្យាស្ថានពិសោធន៍ពូជគោនៅភ្នំតាម៉ៅ
  + រៀបចំសកម្មភាពគម្រោងគាំទ្រដោយសហភាពអឺរ៉ុបទាក់ទងនឹងការងារកែច្នៃទឹកមេជីវិតគោ
  + លើកសំណើទៅភាគីចិនដើម្បីបង្កើតមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតគោ មន្ទីរពិសោធន៍វិភាគចំណីសត្វ មន្ទីរពិសោធន៍សេនេទិច និងមន្ទីរពិសោធន៍កាកសំណល់ថ្នាំ
  + រៀបចំស្នើសុំទិញឧបករណ៍វិភាគចំណីតាមរយៈគម្រោងសហភាពអឺរ៉ុបនិងគម្រោង SPS។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

- ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី ជំងឺសារទឹកចំនួន១៤៦.៥២៦ក្បាល និងជំងឺអុតក្តាមចំនួន៨៧៩ក្បាល

- ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៤.៤៨៨ក្បាល ជំងឺប៉េស្តចំនួន៣.៨៥៦ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៣.៣៧៤ក្បាល ជំងឺអុតក្តាមចំនួន៨៦៤ក្បាល និងជំងឺអូហ្សេស្គីចំនួន៧៦៩ក្បាល

- ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន៥.៩៣១ក្បាល ជំងឺញ៉ូវកាសចំនួន២២.៨០៣ក្បាល ជំងឺអាសន្នរោគចំនួន១៧.១៩២ក្បាល ជំងឺហ្គុមបូរូចំនួន១.៤៥០ក្បាល និងជំងឺប៉េស្តទាចំនួន៦.១៧១ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុពេទ្យ

- ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក
- រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ
- អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅតាមខេត្ត-រាជធានី
- បានពិនិត្យវត្ថុវិភាគសរុបចំនួន១០៩សំណាក និងផ្នែកសរីររោគសាស្ត្រសរុបចំនួន៩ក្បាល
- ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន និងផលិតឡជីវឧស្ម័នសរុបចំនួន១២០ឡ។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

- តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្តទូទាំងប្រទេស សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងវិធានការការពារជំងឺផ្តាសាយបក្សី

- ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមជ្រូកចំនួន៨លើក មាន់ចំនួន៤លើក ទាចំនួន២២លើក កន្លែងពិឃាតមាន់ចំនួន១៦លើក កន្លែងលក់មាន់ចំនួន២០លើក ទ្រុងចិញ្ចឹមចំនួន១១៧លើក និងសត្តឃាតដ្ឋានចំនួន១៥លើក។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

- ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង កំពង់ធំ និងសៀមរាប) ដែលមានសត្វស្លាបប្រមាណ២០៥ប្រភេទ (ប្រហែល១០៦.០៩៩ក្បាល)

- រៀបចំអាហារដ្ឋានត្មាតនៅព្រៃការពារព្រះវិហារ និងសៀមប៉ាង ដោយរាប់ឃើញសត្វត្មាតសរុបចំនួនប្រមាណ១៥០ក្បាល

- ការពារសម្បុកសត្វត្រដក់តូចចំនួនប្រមាណ១១៨សម្បុក សត្វត្រយ៉ងចង្កំ ក ស ចំនួន១២សម្បុក ត្មាតចំនួន៤ និងរំពេរចំនួន១សម្បុក នៅខេត្តស្ទឹងត្រែង ព្រះវិហារ និងក្រចេះ។

### ៤.២ ការងារសហគមន៍ព្រៃឈើ

- ធ្វើការអប់រំផ្សព្វផ្សាយពីសារសំខាន់នៃការអភិរក្សសត្វព្រៃ ពង្រឹងការអនុវត្តច្បាប់ ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់គណៈកម្មាធិការសហគមន៍ ក្រុមសន្សំប្រាក់ ការចិញ្ចឹមមាន់ ការអភិវឌ្ឍកសិកម្មជាលក្ខណៈគ្រួសារ ស្រូវសង្គ្រោះសត្វព្រៃ និងការគ្រប់គ្រងកម្មវិធីទេសចរណ៍ធម្មជាតិចំនួន៤៦លើក ដោយមានអ្នកចូលរួមសរុបចំនួន៨៧២នាក់ (ស្ត្រីចំនួន២៩៨នាក់)

- មានភ្ញៀវទេសចរចំនួន៧៥នាក់មកទស្សនាតំបន់អភិរក្សជីវចម្រុះវ៉ឺនសៃ-សៀមប៉ាង កំពង់ធំ-សៀមរាប តំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្មនិងព្រៃការពារព្រះវិហារដោយសហគមន៍មូលដ្ឋានទទួលប្រាក់ចំណូលចំនួន១.០៥៥ដុល្លារ។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជសង្គ្រាម និងការសង្គ្រោះសត្វព្រៃ

- ក្នុងខែមករា ឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សា៖ សត្វចំណូលថ្មីចំនួន២៤ក្បាល សត្វកើតថ្មីចំនួន៩ក្បាល សត្វដោះលែងចំនួន៣៩ក្បាល សត្វស្លាប់ចំនួន៥ក្បាល ព្យាបាលសត្វចំនួន២២ក្បាល ធ្វើឲ្យសន្លប់ចំនួន១០ក្បាល ទម្លាក់សត្វល្បិតចំនួន៣ក្បាល វះកាត់សាកសពសត្វចំនួន៣ក្បាល ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន៥៨ម$^2$ សង់បង្គោលភ្លើងចំនួន៥ដើម ឆ្ការអនាម័យព្រៃចំនួន១៩.៦១០ម$^2$ និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៦០០នាក់

- ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្ដាមមេ-បាពូជ និងកូនស្វាក្ដាមចំនួន៥៤.៦០០ក្បាល និងបាននាំចេញចំនួន ៣០ក្បាល។

**៤.៤ គម្រោងអភិរក្សសត្វក្រពើភ្នំកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ**

- បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែង ឆាយរាប តំបន់ស្ពានក្រពើក្នុងឃុំតាតៃលើ ខេត្តកោះកុង និងអូរសោម ខេត្តពោធិ៍សាត់

- តាមដានសត្វក្រពើដែលបានដោះលែង១៥ក្បាល តាមរយៈឧបករណ៍វិទ្យុសំឡេង(Radio Tracking)។

**៤.៥ ការងារដាំដើមឈើ**

- ក្រុមហ៊ុន ស៊ីងបាយអូថេក (ខេមបូឌា) ខូអិលធីឌី ជាដៃគូបានធ្វើការកាប់ឆ្ការនិងឈូសឆាយដីព្រៃបានទំហំ៥០ ហិកតា និងយន្តការដាំឈើតាមផែនការ។

**៤.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម**

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញឈើកែច្នៃជូនក្រុមហ៊ុនចំនួន២ ដែលមានបរិមាណឈើកែច្នៃគ្រប់ប្រភេទចំនួន ២.៨១១តោន។

**៤.៧ ការងារចំណូលព្រៃឈើ**

- ផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន ២.៤២៨ម៣ កូនឈើចំនួន៥៣.៣៤១ដើម អុសចម្រុះចំនួន៣.៨០២ស្ទែរ

- ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន១.១៨៩.០៣២.១៦៩រៀល និងចំណូលពីសេវាសាធារណៈ ចំនួន៤០១.២២១.៨៥៦រៀល និង២៧.៥៤៤,៦៨ដុល្លារ។

**៤.៨ ការងារនីតិកម្មនិងវិវាទ**

- បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋាន ទូទាំងប្រទេសចំនួន២៤៥ករណី ដោយបញ្ជូនទៅតុលាការចំនួន២១៨ករណី និងពិន័យអន្តរការណ៍ចំនួន២៧ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន១០០ម៣ ឈើអារចំនួន៧៥៥ម៣ ឈើក្រាក់គ្រញូងចំនួន១៨ម៣និង១.១៥៤គ.ក្រ សត្វព្រៃចម្រុះប្រភេទចំនួន៤៨,៥គ.ក្រនិង១៤៦ក្បាល និងអនុផលព្រៃ ឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន២១០ហិកតាត្រូវបានបញ្ជូនសំណុំរឿងទៅ តុលាការ

- បាននឹងដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃដែលបានទទួលទៅ ក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ(Case Tracking System-CTS) ដើម្បីរៀបចំឲ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប និងការឆ្លើយតបរហ័ស។

## ៥ ផ្នែកជលផល

**៥.១ អាជីវកម្មនេសាទ**

**៥.១.១ នេសាទទឹកសាប**

- ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៤-២០១៥ ក្នុងខែចំនួន២.០០០តោន សរុបបានចំនួន១១.០០០តោន ស្មើ១១០% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១៣.០០០តោន

- នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៥ សរុបបានចំនួន៣០.០០០តោន ស្មើ១០% នៃផែនការ ៣០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០.០០០តោន

- នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៥ សរុបបានចំនួន១០.០០០តោន ស្មើ១១,១១% នៃផែនការ ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១០.០០០តោន(មូលហេតុនៃការថយចុះគឺបណ្ដាលមកពី ការប្រែប្រួលអាកាសធាតុ)។

**៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៥**

- សរុបចំនួន៥.០០០តោន ស្មើ១០% នៃផែនការ៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន ៤.០០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា សរុបបានចំនួន៨.០០០តោន ស្មើ៨% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.០០០តោន

- ការចិញ្ចឹមក្រពើ សរុបបានចំនួន៨.០០០ក្បាល ស្មើ៣,២% នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.០០០ក្បាល

- ការភ្ញាស់កូនត្រីពូជ សរុបបានចំនួនប្រមាណ៩.០០០.០០០កូន ស្មើ៥% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួនប្រមាណ១.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៤-២០១៥ សរុបបានចំនួន៦.០០០តោន ស្មើ៧,៣២% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.០០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៥ សរុបបានចំនួន៧០០តោន ស្មើ៨,៧៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០០តោន

- ការផលិតទឹកត្រី សរុបបានចំនួន៣.០០០.០០០លីត្រ ស្មើ៦% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ សរុបបានចំនួន១.០០០តោន ស្មើ៦,៦៧% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០០តោន

- ផលនេសាទកែច្នៃ សរុបបានចំនួន៥០០តោន ស្មើ១០% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- សម្រាប់ខែមករា ឆ្នាំ២០១៥នេះសំណុំរឿងបទល្មើសជលផលសរុបចំនួន១៧៩ករណីនៅតំបន់ទឹកសាប។ ដោយឡែក ក្នុងខែនេះតំបន់សមុទ្រពុំទាន់មានសកម្មភាពបទល្មើសនៅឡើយទេ។ សមត្ថកិច្ចជំនាញបានបញ្ជូនសំណុំរឿងទៅតុលាការចំនួន១៥ករណី និងបញ្ជូនជនសង្ស័យទៅតុលាការចំនួន២៦នាក់

- សមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាពដោយបំផ្លាញវត្ថុតាងបទល្មើសជលផលរួមមាន របាំងស្បៃមុងនិងសាច់អួនប្រវែង៥៤.៧៤៥ម៉ែត្រ មងប្រវែង១១.១៣៥ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន៧៦៨មាត់ បង្គោល/ចម្រឹងចំនួន២៧.២២៤ដើម អួនហ៊ុមចំនួន២វង់ លប/តុម/ឡើចំនួន៣៣គ្រឿង ឧបករណ៍ឆក់ត្រីចំនួន១៧គ្រឿង ឈ្នក់/ឆ្នុកចំនួន៣គ្រឿង ទូកភ្ជាប់ម៉ាស៊ីនចំនួន១៣គ្រឿង ទូកចំនួន២គ្រឿង សម្រាស់ចំនួន៣.៧៦០ម៉ែត្រក្រឡា របាំងព្រួលប្រវែង២៩០ម៉ែត្រ ម៉ាញ់/នាម/ជនចំនួន៨វង់ ម៉ូតូចំនួន១គ្រឿង មងហ៊ុមចំនួន១វង់ សន្ទូចចំនួន៦.០០០ផ្លែ អាគុយចំនួន២គ្រឿង ដាយចាប់ត្រីចំនួន១មាត់ អួនអូសចំនួន១១វង់ លប(កន្ទុយកណ្តុរ)ចំនួន៤គ្រឿង សំណាញ់ចំនួន២វង់ និងលែងកូនត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន១២.២៨៩គីឡូក្រាម។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល សរុបបានចំនួន២៤.១៤០.០០០រៀល ស្មើ០,៨០% នៃផែនការ៣.០០០.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៤៨៧.៥៥០.០០០រៀល។

### ៥.៧ ការងារអភិរក្សធនធានជលផល និងអភិវឌ្ឍន៍សហគមន៍

- ក្រោយការកែទម្រង់ស៊ីជម្រៅវិស័យជលផលឡូត៍នេសាទទាំងអស់ទូទាំងប្រទេសត្រូវបានរំសាយហើយបង្កើតបានជាកន្លែងអភិរក្សជលផលសរុបចំនួន៤៥១កន្លែង(កន្លែងអភិរក្សជលផលថ្មីចំនួន៥០កន្លែង និងសហគមន៍៣៦៤កន្លែង)

- បង្កើនសកម្មភាពតាមគ្រប់រូបភាពក្នុងការពង្រឹងសហគមន៍នេសាទដែលបានបង្កើតរួចហើយសរុបចំនួន៥១៦ ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន៤៧៧ និងសហគមន៍នេសាទសមុទ្រចំនួន៣៩។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះប្រមូលសំណាកពូជដំណាំ ត្រួតពិនិត្យ វាយតម្លៃ និងជ្រើសរើសទីតាំងសម្រាប់ពិសោធន៍ក្នុងរដូវប្រាំង ព្រមទាំងប្រមូលផលពិសោធន៍ដំណាំដំឡូងមី
- រៀបចំពិសោធន៍ដំណាំសណ្តែកបាយ បន្លែ ព្រមទាំងវាស់វែង និងប្រមូលទិន្នន័យស្រូវវស្សា
- ចុះត្រួតពិនិត្យនិងរៀបចំការងារស្រាវជ្រាវនៅស្ថានីយកោះកេរ្តិ៍ ខេត្តព្រះវិហារ ព្រមទាំងចុះត្រួតពិនិត្យ និងប្រមូលទិន្នន័យពិសោធន៍ដំណាំដំឡូងមី នៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

## ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានាសរុបចំនួន៤៧០ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទសរុបចំនួន៣៣៣ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន៩៣ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល
- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន៧៦៩ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ សរុបចំនួន៩៦ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទសរុបចំនួន៣៤ច្បាប់
- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៨២២នាក់ នារីចំនួន១.៣២៥នាក់ ស្មើនឹង២០% រួមមានៈ
  + អង្គភាពថ្នាក់កណ្តាលចំនួន៤.១៤៨នាក់ ក្នុងនោះនារីចំនួន៧៨៧នាក់ ស្មើនឹង១៩%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៧៦នាក់ ក្នុងនោះនារីចំនួន៥៧៨នាក់ ស្មើនឹង១៧,៨៦%
- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន១៧នាក់ ក្នុងនោះបោះបង់ការងារចំនួន០៦នាក់ សុំលាឈប់ពីការងារចំនួន១០នាក់ និងមរណភាពចំនួន០១នាក់
- ចេញច្បាប់សម្រាកប្រចាំឆ្នាំចំនួន០៩នាក់ ច្បាប់ព្យាបាលជំងឺចំនួន០១នាក់ និងច្បាប់សម្រាកមាតុភាពចំនួន០៣នាក់
- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន០១នាក់ ផ្ទេរចូលក្រសួងចំនួន០១នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន១១នាក់
- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន៨៣នាក់ និងចូលធ្វើការងារវិញចំនួន០១នាក់
- ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន១៥នាក់ សិក្ខាសាលាចំនួន២២នាក់ និងក្នុងប្រទេសចំនួន០៧នាក់
- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៩ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ៩.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបចំនួន១.២៣១នាក់(ស្រី៣៩២នាក់) ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ បន្តរៀបចំកម្មវិធីសិក្សាថ្មី២០១៥ ព្រមទាំងសិក្សាអំពីលទ្ធភាពកាត់បន្ថយចំនួនម៉ោងនិងក្រេឌីតក្នុងក្របខ័ណ្ឌកំណែទម្រង់កម្មវិធីសិក្សាឲ្យបានល្អប្រសើរ និងកំពុងសម្រួលកម្មវិធីសិក្សាលើគ្រប់ជំនាញឲ្យស្របតាមអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤។

ទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែងដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងផលផលតាមគ្រប់រូបភាព។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគាំទ្រផ្សេងៗក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## IV- ទិសដៅអនុវត្តបន្ត

### ១.ផ្នែកដាំដុះ :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ ដើម្បីបានផ្តល់កម្រៃបន្ថែមជួយដល់សេដ្ឋកិច្ចគ្រួសារ

- បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ដើម្បីទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូនៃការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងក្លូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះ។

### ២.ផ្នែកផលិតកម្មនិងបសុព្យាបាល :

- ចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាត់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឲ្យបានទូលំទូលាយ

- ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

- ពង្រឹងត្រួតពិនិត្យចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេស...

ការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឲ្យបានសមស្របតាមនីតិវិធី។

**៣.ផ្នែកព្រៃឈើ** :

- ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើតាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤.ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ជំរុញពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយុទ្ធការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

- បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទដូចភ្លៀងរលឹម។

**៥.ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យមានប្រសិទ្ធភាព

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិឲ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និងយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យនិងចាត់វិធានការសមស្របដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឲ្យបានហ្មត់ចត់

- គ្រោងរៀបចំសន្និបាតកសិករដើម្បីជ្រើសរើសកសិករឆ្នើម និងសន្និបាតបូកសរុបការងារកសិកម្មប្រចាំឆ្នាំ និងលើកទិសដៅអនុវត្តបន្តនាពេលខាងមុខ

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

- បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប៕

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត អ៊ុក រ៉ាប៊ុន